# អនុស្សរណៈ

## រវាង

## រាជរដ្ឋាភិបាលកម្ពុជា ជាមួយ រដ្ឋាភិបាលសហរដ្ឋអាមេរិក
## ដើម្បីបង្កើត និង ដំណើរការគណៈកម្មការរួម កម្ពុជា-អាមេរិក
## សំរាប់ការធ្វើមាតុភូមិនិវត្តន៍

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា (កម្ពុជា) និង រដ្ឋាភិបាលសហរដ្ឋអាមេរិក (សហរដ្ឋ-អាមេរិក) :

-ដោយទទួលស្គាល់នូវកាតព្វកិច្ចជាអន្តរជាតិទៅវិញទៅមក ក្នុងការទទួលយកការវិលត្រឡប់វិញនូវជនជាតិរបស់ខ្លួនតាមលក្ខណៈមនុស្សធម៌ ឆាប់រហ័ស និង មានរបៀបរៀបរយ ។

-ដោយប្រាថ្នាចង់បង្កើត និង ពន្លឿនការពង្រីកទំនាក់ទំនងកិច្ចការអន្តោប្រវេសន៍ជាធម្មតា តាមគោលការណ៍ដែលត្រូវបានទទួលស្គាល់ជាទូទៅនៃច្បាប់ និង ទំលាប់អន្តរជាតិ ។

-ដោយប្រាថ្នាចង់ដាក់អោយចូលជាធរមាននូវគោលការណ៍នានា ដែលបានអនុម័តដោយរដ្ឋទាំងពីរ នៅក្នុងសេចក្តីថ្លែងការណ៍រួម ដែលបានព្រមព្រៀងគ្នានៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០០ និង បន្ទាប់មកត្រូវបានអនុម័តយល់ព្រមដោយសេចក្តីសំរេចរបស់រាជរដ្ឋាភិបាលកម្ពុជា កាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០ ។

-ដោយប្រាថ្នាចង់លើកកម្ពស់បន្ថែមទៀតនូវទំនាក់ទំនងមិត្តភាព និង សហប្រតិបត្តិការរវាងរដ្ឋទាំងពីរ ដោយឈរលើមូលដ្ឋាននៃការគោរពអធិបតេយ្យភាព សមភាព និង ផលប្រយោជន៍ទៅវិញទៅមករបស់រដ្ឋនីមួយៗ ។

បានឯកភាពគ្នា បង្កើតគោលការណ៍ និង វត្ថុបំណងដែលសំដៅគ្រប់គ្រងការបង្កើតឡើង និង កិច្ចដំណើរការរបស់គណៈកម្មការរួមសំរាប់ធ្វើមាតុភូមិនិវត្តន៍ដូចខាងក្រោម :

### គោលការណ៍ជាមូលដ្ឋាន

១-សំណើនៃការធ្វើមាតុភូមិនិវត្តន៍នីមួយៗ គួរត្រូវបានគិតគូរពិចារណា និង សំរេចតាមលក្ខណៈបុគ្គលម្នាក់ៗ តាមករណីនីមួយៗដាច់ដោយឡែកៗពីគ្នា ដោយគ្មានលក្ខ័ណ្ឌជាមុន ។

២-កម្ពុជា និង សហរដ្ឋអាមេរិកត្រូវមានកិច្ចសហប្រតិបត្តិការ ទៅវិញទៅមកក្នុងការបញ្ជាក់ពីសញ្ជាតិរបស់បុគ្គលម្នាក់ៗ និង ពីបញ្ហានានាដែលទាក់ទងដល់ការធ្វើមាតុភូមិនិវត្តន៍ ។

៣-កម្ពុជា និង សហរដ្ឋអាមេរិកសន្យាយ៉ាងមុតមាំ ចំពោះគោលដៅដ៏ចំបងនៃការបញ្ជូនត្រឡប់ជន-ជាតិខ្លួនទៅកាន់ប្រទេសកំណើតគេវិញ ដោយគិតគូរពិចារណានូវទិដ្ឋភាពករុណាធម៌ និង មនុស្សធម៌តាមករណីនីមួយៗ ព្រមទាំងគោលការណ៍នៃសិទ្ធិមនុស្សដែលបានទទួលស្គាល់ជាអន្តរជាតិ ៕

៤-គ្មានខ្លឹមសារណានៅក្នុងឯកសារនេះចាប់បង្ខំ ឬ ត្រូវបានបកស្រាយអោយចាប់បង្ខំដាក់កាតព្វកិច្ចតាមផ្លូវច្បាប់ ឬ ហិរញ្ញវត្ថុទៅលើរដ្ឋណាមួយឡើយ។

## សមាសភាពនៃគណៈកម្មការរួម និង ការរៀបចំកិច្ចប្រជុំ

១-គណៈកម្មការរួមសំរាប់ការធ្វើមាតុភូមិនិវត្តន៍ (គណៈកម្មការ) ត្រូវមានសមាជិក ៤រូប (បួនរូប) មកពីកម្ពុជា និង ៤រូប (បួនរូប) មកពីសហរដ្ឋអាមេរិក តំណាងអោយក្រសួងអន្តោប្រវេសន៍ ការបរទេស និង យុត្តិធម៌ ឬ ក្រសួងសមមូលនៃរដ្ឋនីមួយៗ ។

២-គណៈកម្មការត្រូវជួបប្រជុំគ្នាពីរលើកក្នុងមួយឆ្នាំ ឬតាមការព្រមព្រៀងគ្នានៅពេលវេលា និងទីកន្លែងដែលឯកភាពគ្នា ។

## នីតិវិធី បែបបទសំរាប់ការពិនិត្យសំណើធ្វើមាតុភូមិនិវត្តន៍

១-រដ្ឋនីមួយៗគប្បីចាត់តាំងអាជ្ញាធរកណ្តាលមួយសំរាប់ទទួល និង ពិនិត្យជាបឋមនូវសំណើធ្វើមាតុភូមិ-និវត្តន៍ និង បញ្ហាពាក់ព័ន្ធ ។

២-គណៈកម្មការគប្បីជាវេទិកាបឋម សំរាប់ការពិភាក្សានិង ដោះស្រាយគោលការណ៍ធ្វើមាតុភូមិនិវត្តន៍ជាបុគ្គល ដែលបដិសេធដោយអាជ្ញាធរកណ្តាលនៃរដ្ឋទទួល ។

៣-ប្រសិនបើគ្មានការព្រមព្រៀងគ្នាផ្ទុយពីនេះទេ រាល់សំណើធ្វើមាតុភូមិនិវត្តន៍ ត្រូវបញ្ជូនជាដំបូងទៅកាន់អាជ្ញាធរកណ្តាលនៃរដ្ឋទទួល និង គប្បីត្រូវមាន ÷

ក/ ច្បាប់ចំលងនៃបទបញ្ជាចុងក្រោយឱ្យចាកចេញ ធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋស្នើសុំ ។

ខ/ ច្បាប់ចំលងនៃលិខិតឆ្លងដែនរបស់បុគ្គលនោះ បើសិនជាមាន ឬ ឯកសារដទៃទៀតសំរាប់បង្ហាញភស្តុតាងអំពីអត្តសញ្ញាណ និង ប្រវត្តិរូបរបស់បុគ្គលនោះ និង ឋានៈរបស់ខ្លួនជាជនជាតិនៃរដ្ឋទទួល ។

គ/ ច្បាប់ចំលងនៃកំណត់ហេតុស្តីពីបទល្មើសព្រហ្មទ័ណ្ឌរបស់បុគ្គលនោះ នៅក្នុងរដ្ឋស្នើសុំ ប្រសិនបើមាន។

ឃ/រូបថតដូចគ្នាពីរសន្លឹក និង ស្នាមម្រាមដៃរបស់បុគ្គលនោះ ព្រមទាំងប្រវត្តិសុខភាព ប្រសិនបើមាន ។

ង/ ពត៌មានបន្ថែមនានាដែលអាជ្ញាធរកណ្តាលនៃរដ្ឋទទួលយល់ឃើញថាជាការចាំបាច់ ។

៤-បន្ទាប់ពីបានទទួល និង ពិនិត្យសំណើធ្វើមាតុភូមិនិវត្តន៍រួចហើយ អាជ្ញាធរកណ្តាលនៃរដ្ឋទទួល អាចស្នើសុំជំនួយឧបត្ថម្ភ និង ធនធានពីអាជ្ញាធរកណ្តាលនៃរដ្ឋស្នើសុំ ដើម្បីជួបសម្ភាសន៍ជាមួយបុគ្គលនោះ និង សួរ

បញ្ជាក់ពីពត៌មាននៅក្នុងសំណើ ។

៥-អាជ្ញាធរកណ្តាលនៃរដ្ឋទទួល ត្រូវឆ្លើយតបជាលាយល័ក្ខអក្សរជូនទៅអាជ្ញាធរកណ្តាលនៃរដ្ឋស្នើសុំមិនឱ្យហួសពី ៣០ថ្ងៃ ចាប់ពីថ្ងៃទទួលសំណើ ប្រសិនបើគ្មានការព្រមព្រៀងគ្នាផ្ទុយពីនេះទេ។ ក្នុងករណីមានការបដិសេធ អាជ្ញាធរកណ្តាលនៃរដ្ឋទទួលត្រូវបញ្ជាក់ពីមូលហេតុជាលាយលក្ខ័អក្សរ ហើយគប្បីបញ្ជូនសំណើនេះទៅគណៈកម្មការដើម្បីពិចារណា។ គណៈកម្មការត្រូវពិចារណារាល់សំណើដែលគេបញ្ជូនមក នៅក្នុងការប្រជុំរបស់ខ្លួន។

៦-នៅពេលដែលអាជ្ញាធរកណ្តាលនៃរដ្ឋទទួលយល់ព្រមទទួលយកសំណើធ្វើមាតុភូមិនិវត្តន៍ អាជ្ញាធរនេះគប្បីចេញឯកសារធ្វើដំណើរភ្លាម១ ដែលមានសុពលភាពរយៈពេលយ៉ាងតិច ៦០ថ្ងៃ ដើម្បីអនុញ្ញាតអោយមានការវិលត្រឡប់របស់បុគ្គលនោះ។ រដ្ឋស្នើសុំត្រូវប្រញាប់ប្រញាល់រៀបចំការវិលត្រឡប់របស់បុគ្គលនោះឱ្យបានសមរម្យទៅកាន់រដ្ឋទទួល ហើយត្រូវជំរាបអាជ្ញាធរកណ្តាលនៃរដ្ឋទទួល យ៉ាងហោចណាស់ ប្រាំពីរ (៧) ថ្ងៃការងារជាមុន អំពីដំណើរផ្លូវនៃការវិលត្រឡប់ និង ការគិតគូរពិសេសនានាដូចជា សុខភាព ការពង្រឹងច្បាប់ ឬ ការអមដំណើរដើម្បីការពារ ។

៧-ដរាបណាពុំមានការព្រមព្រៀងផ្ទុយពីនេះ សោហ៊ុយចំណាយទាំងអស់នៃការធ្វើមាតុភូមិនិវត្តន៍ រួមមានការដឹកជញ្ជូនតាមផ្លូវអាកាស និង សេវាកម្មអមដំណើរដើម្បីការពារ ត្រូវទទួលរ៉ាប់រងទាំងស្រុងដោយរដ្ឋស្នើសុំ។

ចុះហត្ថលេខា នៅទីក្រុងភ្នំពេញ នៅថ្ងៃទី២២ ខែមិនា ឆ្នាំ២០០២ ជាពីរច្បាប់ ជាភាសាខ្មែរ និង ភាសា-អង់គ្លេស ច្បាប់ទាំងពីរមានតំលៃស្មើគ្នា។

| ជំនួសរាជរដ្ឋាភិបាលកម្ពុជា | ជំនួសរដ្ឋាភិបាលសហរដ្ឋអាមេរិក |
| --- | --- |
| ឧត្តមសេនីយ៍ឯក ឯម សំអាន | ខិន វីឌីមិន |
| រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក |